ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ:...២៥៥.........PC អ.ក

# សេចក្តីជូនដំណឹងលើកទី២
## ស្តីពី
## ការផ្គត់ផ្គង់ និង តម្លើងម៉ាស៊ីនត្រជាក់ ចំនួន ០៦គ្រឿង
## ជូនសាខាចាក់អង្រែក្រោម នៃនាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា: អគ្គិសនីកម្ពុជា នឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការងារ ស្តីពីការផ្គត់ផ្គង់ និង តម្លើងម៉ាស៊ីនត្រជាក់ ចំនួន ០៦គ្រឿង ជូនសាខាចាក់អង្រែក្រោម នៃនាយកដ្ឋានអាជីវកម្មចែកចាយ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាសយដ្ឋាន៖ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ( ទូរស័ព្ទទំនាក់ទំនង៖ 023 67 66 007 និងWebsite: www.edc.com.kh )

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ១១ : ០០ នាទី។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៦:១៥នាទី ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ.សុក្រ...១៣រោច...ខែ..មាឃ.....ឆ្នាំរការ នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ, ថ្ងៃ.....១៦.....ខែ..កុម្ភៈ...ឆ្នាំ២០១៨
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**នឹង អ៊ីង**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ